# ១៩- រឿង សួស្តី និងអពមង្គល

សម័យមួយ សិរីសួស្តី និងអពមង្គល ជួបនិយាយគ្នា ។ អពមង្គលសួរទៅសិរីសួស្តីថា << លោកមានរឹទ្ធិអំណាច ដូចម្តេចខ្លះ ? » ។ សិរីសួស្តី ប្រាប់ទៅអពមង្គលថា << រឹទ្ធិអំណាចអញជាសិរីសួស្តីនេះ ខ្លាំងពូកែណាស់ សូម្បីតែមនុស្សខ្ញុំគេ ទោះគេស្អប់ គេមិនមេត្តា តែអញទៅសណ្ឋិតកាលណា នឹងបណ្តាលឲ្យគេស្នេហាទំនុកបម្រុង ដរាបដល់បានរាជសម្បត្តិ » ។

ឯសិរីសួស្តី សួរទៅអពមង្គលវិញថា «រឹទ្ធិអំណាច ដូចម្តេចខ្លះ ?» ។ អពមង្គលឆ្លើយថា «រឹទ្ធិអំណាចខ្ញុំនេះ បើខ្ញុំទៅសណ្ឋិតនៅឈ្មោះណាបណ្តាលឲ្យគេស្អប់គេខឹង ខូចខាតសម្បត្តិទ្រព្យវិនាសអន្តរាយ សូម្បីតែបានរាជសម្បត្តិហើយក៏គង់ថ្លោះធ្លោយ ធ្លាក់ខ្លួនទៅជាខ្ញុំគេបាន» ។ អពមង្គលចង់ដឹងរឹទ្ធិសិរីសួស្តី ក៏ប្រាប់ថា «ខ្ញុំឃើញខ្ញុំសេដ្ឋីម្នាក់ឈ្មោះអាគុល សព្វថ្ងៃនេះ សេដ្ឋីប្រើឲ្យឃ្វាលគោក្របី សេដ្ឋីខឹងនឹងអាគុល ជេរវាយតែសព្វថ្ងៃ ថាពុំមើលថែរក្សាគោក្របី ឲ្យស្គមអស់ ខ្ញុំចង់ឲ្យលោកសិរីសួស្តីទៅសណ្ឋិតនៅលើរូបអាគុលខ្ញុំសេដ្ឋីនោះ, បើវាបានរាជសម្បត្តិ ខ្ញុំក៏ជឿថាលោកមានរិទ្ធិខ្លាំងពូកែប្រាកដមែន » ។ សិរីសួស្តីប្រាប់អពមង្គលវិញថា « ឯងចាំមកគន់មើលចុះ ថ្ងៃស្អែកនេះ អញចូលទៅសណ្ឋិតនៅលើរូបអាគុល ខ្ញុំសេដ្ឋីហើយ, តែកាលណាអញចូលទៅនៅហើយ មិនយូរប៉ុន្មានមុខជាអាគុលខ្ញុំសេដ្ឋីនោះ វាបានសោយរាជសម្បត្តិមិនខាន » ។

លុះព្រឹកឡើង ដល់ពេលអាគុលបញ្ចេញគោក្របីពីក្រោល យកទៅឃ្វាល, សិរីសួស្តីចូលទៅសណ្ឋិតនៅលើរូបអាគុល ៗ ក៏រីករាយ សប្បាយក្នុងចិត្តប្លែកពីថ្ងៃមុន ។

ដល់ពេលល្ងាច អាគុលកៀងគោក្របី ត្រឡប់មកបញ្ចូលក្រោលឯផ្ទះវិញ ។ សេដ្ឋីទាំងប្តីប្រពន្ធឈរមើលគោក្របី ឃើញអាគុលរាំងទ្វារក្រោលគោក្របីខ្ទាប់ហើយ ទើបឡើងទៅអង្គុយលើផ្ទះសេដ្ឋីជាចៅហ្វាយ នៅត្រង់កន្លែងខ្លួន ដូចសព្វដង ។ កាលសេដ្ឋីទាំងប្តីប្រពន្ធ ឃើញអាគុលហើយ ក៏នឹកក្នុងចិត្តអាណិតថា «ឱអាគុលអើយ ! ទៅឃ្វាលគោក្របី អត់បាយក្រហាយទឹកទាល់ល្ងាច ទើបបានបាយបរិភោគ ម្ល៉េះសមវាឃ្លានយ៉ាងណាទៅ ? គិតហើយក៏ដាស់តឿនខ្ញុំកំដរស្រីៗ ឲ្យដោះដួសបាយស៊ីរាល់គ្នា ។ខ្ញុំស្រីៗក៏ដោះដួសភោជនាហារណា ដែលមានឱជារសយកទៅដាក់ជូនសេដ្ឋី ហើយប្រជុំគ្នាបរិភោគ ។ សេដ្ឋីប្តីប្រពន្ធ ហៅអាគុលឲ្យមកជិត ចាប់ម្ហូបដែលមានឱជារសឲ្យបរិភោគ ។រួច សេដ្ឋីប្តីប្រពន្ធគន់មើលកិរិយាឫករូបអាគុលនោះ ក៏ឃើញថាសមរម្យឥតខ្ចោះ រកទាស់ចិត្តត្រង់ណាគ្មាន ។ បណ្តាជនទាំងស្រីប្រុស ឲ្យតែឃើញរូបអាគុលនោះកាលណា ក៏មានចិត្តស្នេហាមេត្តាពន់ប្រមាណ ។ ឯសេដ្ឋីប្តីប្រពន្ធជាចៅហ្វាយអាគុលនោះ និយាយគិតគ្នាថា « សព្វថ្ងៃនេះ យើងឥតកូន, ទ្រព្យសម្បត្តិក៏មានច្រើន, អំណើះតទៅបើឥតពីយើង ទ្រព្យសម្បត្តិនឹងអន្តរាយអសារឥតការ, គួរលើកអាគុលឡើងតម្កើងធ្វើជាកូន កុំឲ្យវាឃ្វាលគោក្របីទៀត ត្បិតអាគុលនេះ សាច់ឈាមឫកពាល្អណាស់ល្មមសមគួរជាកូនយើងបាន » ។

ដល់ពេលល្ងាច អាគុលត្រឡប់មកពីឃ្វាលគោក្របីវិញ សេដ្ឋីទាំងប្តីប្រពន្ធ ឃើញអាគុលរឹតតែស្នេហាមេត្តាពន់ពេក ក៏ហៅឲ្យបរិភោគបាយជាមួយមិនឃ្លាតឆ្ងាយពីខ្លួន ឈប់ឲ្យឃ្វាលគោក្របី ចាប់តាំងពីថ្ងៃនោះតទៅ ។

សេដ្ឋីទាំងប្ដីប្រពន្ធ យកសំលៀកបំពាក់ គ្រឿងមាសប្រាក់មកតុបតែងឲ្យអាតុលហើយប្រាប់ថា «ពីថ្ងៃនេះទៅ អញទុកឯងជាកូន, អំណើះពីអញទៅ ទ្រព្យសម្បត្តិអញទាំងប៉ុន្មាន នៅលើដៃកូនឯងទាំងអស់ » ។ អាតុលក៏រីករាយសប្បាយជាទីបំផុត ។

ដោយអំណាចសិរីសួស្ដី សណ្ឋិតលើខ្លួន លុះអាតុលចំរើនអាយុពេញរូបរាងឡើង ក៏រឹតតែល្អ រកបុរសឯណានឹងប្រៀបផ្ទឹមស្មើពុំបាន ។

រាល់ព្រឹកល្ងាច សេដ្ឋីតែងចូលគាល់ព្រះមហាក្សត្រ ពុំដែលលស់ខាន ក៏នាំយកអាតុលជាកូនទៅគាល់ផង ។ ព្រះរាជាទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គ ស្ដេចចេញប្រថាប់នៅក្រឡាព្រះនៅផ្ចូល់ ព្រះរាជបុត្រី ក៏ដិតដោយក្រោយព្រះអង្គមក ។ កាលមហាសេដ្ឋីនាំកូនចូលក្រាបបង្គំគាល់ព្រះមហាក្សត្រ ទ្រង់ឆ្មៀងព្រះនេត្រ ឃើញសេដ្ឋីនិងកូនអង្គុយគាល់ទន្ទឹមគ្នា ទ្រង់ត្រាស់សួរថា « កូនសេដ្ឋីឬ ? សេដ្ឋីទូលថា « កូនទូលព្រះបង្គំជាខ្ញុំ » ។ ស្ដេចទ្រង់សរសើរថា « កូនសេដ្ឋីមានរូបមានឫកល្អណាស់ »។ ព្រះរាជបុត្រី ក៏នឹកក្នុងព្រះទ័យថា « កូនសេដ្ឋីនោះមានលំអនឹងរកបុរសណាផ្ទឹមពុំបាន ធ្វើម្ដេចនឹងបានជាស្វាមីអញ ?

ដល់ពេលគួរ ស្ដេចនិងព្រះរាជបុត្រីនោះ យាងចូលទៅខាងក្នុងវិញ, សេដ្ឋីក្រាបថ្វាយបង្គំលា នាំកូនត្រឡប់មកផ្ទះ, ដល់ផ្ទះកូននិយាយនឹងសេដ្ឋីថា «សូមលោកឪលោកម៉ែមេត្តាកូន ទៅដណ្ដឹងព្រះរាជបុត្រីស្ដេចឲ្យខ្ញុំ ត្បិតកាលខ្ញុំចូលទៅគាល់ជាមួយលោកឪពុកនោះ, ខ្ញុំបាទឃើញច្បាស់ព្រះរាជបុត្រីនោះល្អណាស់ បើមិនដណ្ដឹងឲ្យខ្ញុំទេ ខ្ញុំមុខជាស្លាប់មិនខាន» ។ ដោយស្នេហាកូនពេក សេដ្ឋីប្ដីប្រពន្ធក៏ប្រថុយខ្លួនរៀបតុមាសប្រាក់ ដាក់គ្រឿងបណ្ណាការជាតង្វាយសុទ្ធតែពេជ្រនិងមាសពោរពាសច្រើនតុ, លុះព្រឹកឡើងនាំតង្វាយនោះទៅរៀបចំក្នុងទីព្រះរាជវាំង ។ ព្រះមហាក្សត្រ ស្ដេចចេញមកឲ្យនាហ្មឺនធំតូចគាល់ ។ សេដ្ឋីទាំងប្ដីប្រពន្ធ ក៏គាល់នៅជិតគ្រឿងបណ្ណាការតង្វាយនោះ ។ ស្ដេចត្រាស់សួរថា « សេដ្ឋី ! តង្វាយនេះ ប្លែកណាស់ មានការអ្វី ? » ។ សេដ្ឋីប្ដីប្រពន្ធក្រាបបង្គំទូលថា « សូមព្រះរាជតេជះតម្កល់លើត្បូង សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ សូមទ្រង់ប្រោសព្រះរាជទានព្រះរាជបុត្រី ផ្សំនឹងកូនទូលព្រះបង្គំជាខ្ញុំ » ។ ស្ដេចទ្រង់ជ្រាប ទ្រង់ព្រះរាជអនុញ្ញាត ទ្រង់ចាត់មុខក្រសួង ឲ្យរៀបព្រះរាជពិធីសមោសរ, ហោរាថ្វាយឫក្ស ទ្រង់ផ្សំព្រះរាជបុត្រីនឹងកូនសេដ្ឋី ហើយផ្ទេរទាំងរាជសម្បត្តិឲ្យគ្រប់គ្រងផង ។

លុះបានរាជសម្បត្តិហើយ ស្ដេចតុលនិងព្រះនាងមហេសី ក៏បានប្រកបសេចក្ដីសុខឥតទុក្ខា មហាប្រសើររៀងទៅ ។

និយាយពីរឿងអពមង្គលវិញ កាលជួបនឹងសិរីសួស្ដីក៏ថា «លោកសិរីសួស្ដីខ្ញុំជឿហើយឃើញថា លោកមានរឹទ្ធិជួយស្ដេចតុលឲ្យបានរាជសម្បត្តិមែន, ដូច្នេះលោកចាំមើលរឹទ្ធិខ្ញុំវិញម្ដង សូមលោកលែងសណ្ឋិតនៅលើរូបស្ដេចតុលទៅ » ។ សិរីសួស្ដីក៏ថយចេញពីរូបស្ដេចតុល, អពមង្គលក៏ចូលទៅសណ្ឋិតលើរូបស្ដេចតុលម្ដង ។ ឯស្ដេចតុលចេះតែមួម៉ៅ ក្ដៅក្រហាយ, ព្រះនាងមហេសីស្រីបរិវារ ក៏ពុំសូវយកចិត្តទុកដាក់គោរពប្រណិប័តន៍ បណ្ដាលចិត្តឲ្យតែខឹងស្អប់ស្ដេចតុល អស់លោកចតុស្តម្ភទាំងប៉ុន្មាន ៗ ក៏ពុំសូវចូលចិត្តគិតចង់ឲ្យតែព្រះវររាជបិតាក្មេក យករាជ្យសម្បត្តិទៅវិញ ។

ចំណែកស្ដេចតុល ចេះតែក្ដៅក្រហាយអន្ទះអន្ទែង ចង់ទៅក្រសាលទីទំនាបមាត់បឹងក្រៃពេក ក៏នាំព្រះនាងមហេសីស្រីបរិវារចេញទៅ, លុះទៅដល់ក៏ឲ្យធ្វើព្រះពន្លាស្នាក់ក្រសាល ។ នៅទីមាត់បឹងនោះ ឮតែសព្ទសូរត្រដោកគោត្រដោកក្របី, ស្ដេចតុលក៏ភ្នកនឹកអាណិតខ្លួនកាលនៅជាខ្ញុំមហាសេដ្ឋី ដែលគេប្រើឲ្យឃ្វាលក្របី ហើយក៏ទ្រង់ព្រះកន្សែងខ្សឹកខ្សួល ។ ព្រះនាងមហេសីសួរថា «ព្រះអង្គ ! ហេតុអ្វីក៏ទ្រង់ខ្សឹកខ្សួលម្ល៉េះ ?»។ ស្ដេចតុលប្រាប់ព្រះនាងមហេសីតាមត្រង់ថា «លាក់បាំងអី ម្ចាស់អូនអើយ ! ខ្លួនបងនេះ មិនមែនកូនសេដ្ឋីទេ, ពីដើមបងជាខ្ញុំសេដ្ឋី ។ គេប្រើឲ្យឃ្វាលគោក្របី ឥឡូវឮត្រដោកក្របីគោ បងនឹកស្រងេះស្រងោចអាណិតខ្លួន បានជាបងយំ » ។ ព្រះនាងមហេសីបានឮថាជាខ្ញុំសេដ្ឋី ក៏មានចិត្តទោមនស្សក្នុងព្រះទ័យពន់ពេកថា « ឱព្រះវរបិតា ពុំគួរផ្សំផ្គុំកូន ផ្ទេរទាំងរាជសម្បត្តិឲ្យទៅខ្ញុំគេសោះ » ខ្ចាល់ហើយក៏នាំស្ដេចតុលនឹងស្រីបរិវារ ដែលតាមហែទៅទាំងប៉ុន្មាន ត្រឡប់ចូលព្រះរាជវាំងវិញ ចូលក្រាបទូលវររាជបិតាមាតា តាមរឿងដែលស្ដេចតុលយំគ្រប់ប្រការ ។ ស្ដេចជាព្រះវររាជបិតាមាតាទ្រង់ជ្រាបហើយទ្រង់ក្រោធពន់ប្រមាណ ទ្រង់ត្រាស់ឲ្យហៅសេដ្ឋីទាំងប្ដីប្រពន្ធមកដៀលត្មះជាទម្ងន់ ហើយប្រគល់ស្ដេចតុល ឲ្យទៅសេដ្ឋីប្ដីប្រពន្ធ នាំយកទៅផ្ទះវិញ ។

ឯរាជសម្បត្តិ ស្ដេចទ្រង់គ្រប់គ្រងវិញ ។ សេដ្ឋីប្ដីប្រពន្ធនាំអាតុលទៅដល់ផ្ទះហើយជេរវាយ ត្មះតិះដៀល លែងរាប់អានជាកូន ឲ្យអាតុលឃ្វាលគោក្របីទុកជាខ្ញុំដូចដើម ។

**មារយាទថ្លៃឲ្យយក មារយាទថោកឲ្យវៀរ។**